ការសម្ភាសរបស់លោកពូ ភិន សាយ

ក៖ អ្នកសម្ភាសឈ្មោះជាង ស៊ីអ៊ាវ ខ៖ អ្នកទទួលការសម្ភាសឈ្មោះ ភិន សាយ។

ការសង្ខេបប្រវត្តិរបស់អ៊ុំប្រុស ភិន សាយ

អ៊ុំប្រុសភិន សាយ មានអាយុ៥៦ ឆ្នាំនៅក្នុងឆ្នាំ២០១៩ ភេទប្រុស អាស័យដ្ឋានបច្ចុប្បន្ននៅភូមិ គោកស្រុក ឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។

ក៖ ចឹងជាដំបូងខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ុំទាក់ទងពីប្រវត្តិរបស់អ៊ុំ ហើយការសម្ភាសទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយពួកគាត់បានស្គាល់ ហ្នឹងបានដឹងពីប្រវត្តិឪពុកម្តាយហ្នឹងដូនតាចឹងសំរាប់អ៊ុយល់ព្រមដើម្បីអោយក្លួយដាក់ការសម្ភាសទាំងអស់ហ្នឹងទៅក្នុងវេបសាយសាលាទេអ៊ុ?

ខ៖ បាទ!

ក៖ បាទអ៊ុចឹងសំរាប់ខ្ញុំជាអ្នកសម្ភាសអ៊ុខ្ញុំមានឈ្មោះថាជាងស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសម្ភាសអ៊ុគឺនៅថ្ងៃទី៨ ខែ៣ឆ្នាំ២០១៩ហើយការសម្ភាសទាំងអស់ហ្នឹងគឺធ្វើឡើងនៅភូមិគោកស្រុក ឃុំតាំងក្រសៅ អើស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ!

ខ៖ បាទ!

ក៖ ចឹងសំរាប់អ៊ុឈ្មោះអ៊ុទាំងត្រកូលឈ្មោះអីគេអ៊ុ?

ខ៖ ខ្ញុំឈ្មោះ..!

ក៖ ឈ្មោះអ៊ុទាំងត្រកូលម៉ងហាស?

ខ៖ ភិន សាយ។

ក៖ ភិន សាច?

ខ៖ ភិន សាយ។

ក៖ ភិន សាយ?

ខ៖ បាទ!

ក៖ អ៊ូចុះមានឈ្មោះហៅក្រៅអត់អ៊ុ?

ខ៖ បាទ?

ក៖ មានឈ្មោះហៅក្រៅអត់?

ខ៖ អត់មានតែមួយហ្នឹងឯង!

ក៖ អ៊ូកាលពីក្មេងក៏អត់ធ្លាប់មាននរណាហៅឈ្មោះអ៊ុអត់ទេ?

ខ៖ អត់មានទេមានតែមួយហ្នឹង!

ក៖ អ៊ូចុះអ៊ុគិតថាសព្វថ្ងៃអ៊ុអាយុប៉ុន្មានអ៊ុ?

ខ៖ ហាជាង។

ក៖ អ៊ុហាប៉ុន្មានហើយអ៊ុ?

ខ៖ ដឹងហាប៉ុន្មានទេហាប្រាំហាប្រាំមួយទេដឹង។

ក៖ អ៊ូអ៊ុកើតនៅថ្ងៃខែឆ្នាំណាអ៊ុ?

ខ៖ អ៊ូអត់ចាំទេភ្លេចទៅហើយ!

ក៖ តែអ៊ុហាប្រាំរឺហាប្រាំមួយអ៊ុ?

ខ៖ អត់ទៀងដែរបើមិនហាប្រាំហាប្រាំមួយ។

ក៖ ខ្ទង់ប៉ុណ្ណឹងណេះអ៊ុណេះ?

ខ៖ ខ្ទង់ប៉ុណ្ណឹង។
ក៖ អ្វ៉ចុះឆ្នាំចន្ទគតិជូត ឆ្លូវ ខាល ថោះអ៊ីឆ្នាំអីគេអ៊ី?
ខ៖ ឆ្នាំដែងថោះ។
ក៖ អ៊ីឆ្នាំថោះ?
ខ៖ បាទ!
ក៖ អ្វ៉ចុះអ៊ីស្រុកកំណើតដែរអ៊ីកើតម៉ងអ៊ីកើតនៅណាអ៊ី?
ខ៖ កើតនៅចំបក់តាំងក្រសាំង។
ក៖ ចំបក់តាំងក្រសាំងហោស?
ខ៖ បាទ!
ក៖ អ្វ៉ប៉ុន្តែយុំហ្នឹងដែរណេះអ៊ីណេះ?
ខ៖ យុំណែដែង..!
ក៖ តាំងក្រសៅហ្នឹងដែរ?
ខ៖ តាំងក្រសាំង។
ក៖ តាំងក្រសាំងហោស?
ខ៖ បាទ!
ក៖ អ៊ីបាទអ៊ីចុះអ៊ីគិតថាដូចជាចឹងអ៊ីមានបងប្អូនបង្កើតចំនួនប៉ុន្ថាននាក់?
ខ៖ បងប្អូនបង្កើតងាប់អស់ទៅហើយ!
ក៖ អ្វ៉ប៉ុន្តែទាំងអស់ប៉ុន្ថាននាក់?
ខ៖ ប្រាំនាក់។
ក៖ ប្រាំនាក់ចឹងមានន័យថាសល់តែអ៊ីមួយទេ?
ខ៖ នៅតែមួយហ៉ៅនៅពីរប៉ុនមួយទៀតនៅឆ្ងាយ។
ក៖ គាត់នៅណា?
ខ៖ នៅអ៊ីឡាវហោស!
ក៖ គាត់នៅឡាវហោស?
ខ៖ បាទ!
ក៖ គាត់ទៅធ្វើអីគេនៅណុង?
ខ៖ បងទីពីរ។
ក៖ តែគាត់ធ្វើអីគេនៅណុង?
ខ៖ បានប្រពន្ធនៅហ្នឹង!
ក៖ អ្វ៉ចុះអ៊ីគិតថាអើអ៊ីជាកូនទីប៉ុន្ថាន?
ខ៖ ខ្ញុំពៅគេ។
ក៖ ពៅគេហោស?
ខ៖ បាទ!
ក៖ អ្វ៉មានស្រីប៉ុន្ថានប្រុសប៉ុន្ថានអ៊ី?
ខ៖ ស្រីមួយ។
ក៖ ស្រីមួយប្រុសបួន?
ខ៖ ប្រុសបួន។
ក៖ តែស្លាប់អស់បីនាក់?
ខ៖ ស្លាប់បី។
ក៖ ចុះបងធំឈ្មោះអីគេខ្លះអ៊ី?
ខ៖ ស៊ីន។
ក៖ ចុះបងទីពីរ?
ខ៖ សៃ។
ក៖ បងទីបី?
ខ៖ សេងណែបងទីបីស្រី។
ក៖ ដល់បងទីបួន?
ខ៖ សេង។

ក៖ ដល់ពេលទីជ្រាំអ៊ីសាយ?
ខ៖ បាទ!
ក៖
អ្ហ៎បាទអ៊ីចុះអ៊ីគិតថាអើបងៗរបស់អ៊ីដែរគាត់ស្លាប់នៅជំនាន់ណាជំនាន់ហ្នឹងតើហី
?
ខ៖ បងខ្ញុំបងគេបង្អស់ស្លាប់ពេលយើងដាច់ប៉ុលពាត។
ក៖ អ្ហ៎ចុះទីបីទីបួន?
ខ៖ ទីបីស្លាប់ពេលគាត់នៅបានដីមកនៅនេះ។
ក៖ ចុះទីបួន?
ខ៖ ទីបួនស្លាប់នៅពេលគេប្លន់យកក្របីវាលក្រោម។
ក៖
អ្ហ៎បាទអ៊ីចុះអ៊ីគិតថាដូចជាបងដូចជាបងប្អូនរបស់អ៊ីអ៊ីធ្លាប់មានអនុស្សាវរីយ៍ជា
មួយគាត់ធ្លាប់ធ្វើការងារជាមួយគាត់រឺមួយក៏ធ្លាប់ទៅស្រែ?
ខ៖ បាទ!
ក៖ ជាមួយគាត់ដែរតើហីអ៊ី?
ខ៖ ជាមួយធ្លាប់ធ្វើឆ្លងកាត់ជាមួយគ្នា។
ក៖ ធ្លាប់ទៅចាប់ត្រី?
ខ៖ បាទ!
ក៖ ចាប់ក្តាមជាមួយគ្នាណេះពូអ៊ីណេះ?
ខ៖ ជាមួយគ្នា។
ក៖ តែអ៊ីចូលចិត្តធ្វើអីគេជាមួយបងប្អូនអ៊ី?
ខ៖ ខ្ញុំចូលចិត្តទៅធ្វើអីធ្វើតែស្រែកត្រីហូប។
ក៖ បាទអ៊ីបាទ!
ខ៖ មានមុខរបរអីនៅវែងឆ្ងាយយើងកាលនោះមានទៅរកតែត្រី។
ក៖ បាទអ៊ីបាទ!
ខ៖ ធ្វើស្រែខែធ្វើស្រែយើងធ្វើស្រែ។
ក៖ បាទអ៊ីចុះអ៊ីគិតថាដូចជាបងអ៊ីទាំងពីរគាត់នៅឡាវ?
ខ៖ បាទ!
ក៖ ចុះគាត់ម៉េចបានគាត់បានប្រពន្ធឡាវ?
ខ៖ គាត់ធ្វើទាហ៊ានៅដែងខាងខេត្តកំពង់ចាម។
ក៖ អ្ហ៎បាទ!
ខ៖ គាត់ធ្វើនោះទៅគាត់បានប្រពន្ធទៅក៏ប្រពន្ធទៅនៅនោះស្រុកកំណើត។
ក៖ ចុះគាត់ធ្វើអីគេនៅណុងអ៊ី?
ខ៖ គាត់ដាំចំការយើងធម្មតា។
ក៖ នៅឡាវហ្នឹងហោស?
ខ៖ បាទ!
ក៖ អ្ហ៎!
ខ៖ ដាំចំការសណ្តែកយើងធម្មតា។
ក៖ ចឹងមានន័យថាគាត់ចេះឡាវហើយណេះអ៊ីណេះ?
ខ៖ គាត់មិនចេះទេគាត់នៅក្រោយថាទៅអែបព្រាំប្រទល់គាត់នៅខ្ទែរយើងទេ។
ក៖ ប៉ុន្តែគ្រាន់ថាគាត់នៅជាប់ព្រាំប្រទល់ឡាវ?
ខ៖ បាទជាប់ព្រាំប្រទល់ឡាវ។
ក៖ អ្ហ៎បាទចុះអ៊ីគិតថាឪពុករបស់អ៊ីឈ្មោះអីគេអ៊ី?
ខ៖ ឪពុកបង្កើតហោស?
ក៖ បាទ!
ខ៖ សែម។
ក៖ ប៉ុន្តែត្រកូលអីគេអ៊ី?

ខ៖ រដ្ឋ។
ក៖ រដ្ឋ សែម?
ខ៖ បាទ!
ក៖ ចុះម្តាយឈ្មោះអីគេ?
ខ៖ គីម។
ក៖ ចុះត្រកូលគាត់ហោស?
ខ៖ ត្រកូលគាត់ទាប។
ក៖ តាប គីម?
ខ៖ ទាប គីម។
ក៖ អ្ហ៉ឌីពុកម្តាយរបស់អ៊ីគាត់កើតនៅហ្នឹងរឺនៅណាអ៊ុ?
ខ៖ នៅអ៊ុណោះនៅច្របក់តាំងក្រសាំង។
ក៖ ច្របក់តាំងក្រសាំងហោស?
ខ៖ បាទ!
ក៖
អ្ហ៉ចុះអើអ៊ុគិតថាឌីពុករបស់អ៊ុកាលគាត់នៅរស់គាត់ធ្វើអីគេគាត់ស្លាប់អស់ហើយណោះអ៊ុ?
ខ៖ គាត់ស្លាប់អស់ហើយស្លាប់អស់ទាំងអស់។
ក៖
បាទអ៊ុចុះអ៊ុគិតថាឌីពុករបស់អ៊ុកាលគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមចៅហាស?
ខ៖ គាត់ដូចតែខ្ជុំរកដែរហ្នឹងហាស!
ក៖ រកត្រី..?
ខ៖ រកត្រីធ្វើតែស្រែ។
ក៖ អ្ហ៉ចឹងមានន័យថាអ៊ុធ្វើស្រែ?
ខ៖ បាទ!
ក៖ អ៊ីមានស្រែខ្លួនឯងប៉ុន្មានទៅ?
ខ៖ អើខ្ជុំមានស្រែតិចតួចទេសព្វថ្ងៃនេះ។
ក៖ ស្រែអ៊ុដល់ណាទៅ?
ខ៖ នៅជំនៀងហោស!
ក៖ នៅជំនាងហោស?
ខ៖ បាទ!
ក៖ អ្ហ៉!
ខ៖ ស្រែតិចស្រែមិនបានមួយហត្ថផង។
ក៖ បាទអ៊ុបាទចុះអ៊ុគិតថាអើត្រីអ៊ុរកនៅណា?
ខ៖ បាទ!
ក៖ ត្រី?
ខ៖ អើដើរច្រេកច្រកៗតាមបឹងត្រពាំងតូចតាចអស់នេះឯង។
ក៖ អ្ហ៉ប៉ុន្តែរកបានច្រើនទេអ៊ុ?
ខ៖ ទេបានជួនកាលបានទៅជួនកាលអត់ទៅជួនកាលបានមួយគីឡអីទៅ។
ក៖ អ្ហ៉!
ខ៖ ត្រាន់ដោះស្រាយជីវភាពក្នុងក្រុមគ្រួសាររបស់យើងនេះ។
ក៖ បាទអ៊ុបាទប៉ុន្តែចេះតែរក..?
ខ៖ អោយរកបានលក់ដូរហ្នឹងគេរកមិនបានទេ។
ក៖ ចឹងចេះតែរកបានរាល់ថ្ងៃហើយណោះអ៊ុណោះ?
ខ៖ រកចេះតែបានតិកតក់ៗដោះស្រាយជីវភាពក្នុងក្រុមគ្រួសាររបស់យើង។
ក៖ អ្ហ៉បាទអ៊ុបាទ!
ខ៖ មិនសូវយ៉ាប់ទិញគេ។

ក៖ បាទអ៊ុ!
ខ៖ ប៉ុនមើលថ្ងៃណាមិនសូវរៀងស្រួលខ្លួនទិញគេដែរណាស់។
ក៖ អ៊ូ!
ខ៖ ប៉ុនយ៉ាប់ទាំងអារកលុយទិញគេក្មានទៀតហ្នឹងហាស!
ក៖
អ៊ូបាទអ៊ុចុះអ៊ុគិតថាអើម្តាយរបស់អ៊ុវិញគាត់ធ្វើការអីសំរាប់ចិញ្ចឹមជីវិតចិញ្ចឹមកូនចៅអ៊ុ?
ខ៖ ម្តាយខ្ញុំ។
ក៖ បាទ!
ខ៖ ម្តាយខ្ញុំបង្កើតហោស?
ក៖ បាទ!
ខ៖ បើខ្ញុំកើតមកមិនទាន់គាត់ផង។
ក៖ អត់ទាន់ទេណោះអ៊ុណោះ?
ខ៖ គាត់ក្រាន់តែបង្កើតខ្ញុំ។
ក៖ អ៊ូបាទអ៊ុបាទ!
ខ៖ បើខ្ញុំនៅកូនអាបៅដោះគេតើខ្ញុំ។
ក៖ អ៊ូចឹងហោសអ៊ុ?
ខ៖
បាទរួចគាត់ទៅឪខ្ញុំទេខ្ញុំលីតែអ៊ុៗខ្ញុំនិយាយគាត់ថាឪខ្ញុំទៅធ្វើសង្គ្រាមរួចទៅគាត់ទៅមើលខ្ញុំហាស!
ក៖ បាទអ៊ុបាទ!
ខ៖ រួចទៅគាត់ក៏មានប្រុសដែងពួកលុនណុលហោស!
ក៖ បាទអ៊ុ!
ខ៖ ខ្ញុំកើតជំនាន់លុនណុល។
ក៖ អ៊ូបាទ!
ខ៖
ដល់ពេលរួចទៅគាត់យកប្តីលុនណុលទៅទុកខ្ញុំនៅចោលបានតាខ្ញុំហ្នឹងអ៊ុខ្ញុំទៅយកខ្ញុំទៅមើល។
ក៖ អ៊ូ!
ខ៖ មើលថែអោយបៅតែទឹកដោះម្តាយមីងទេខ្ញុំមិនដឹងមុខម្តាយម៉េចទេ។
ក៖ អ៊ូ!
ខ៖ ប៉ុនខ្ញុំស្គាល់ដែរស្គាល់ថាម៉ែឈ្មោះនេះឈ្មោះនោះ។
ក៖ បាទអ៊ុ!
ខ៖ ខ្ញុំស្គាល់តាមគេពេលខ្ញុំធំនេះទេ។
ក៖ អ៊ូបើថាអោយឃើញមុខអត់ទាន់ទេ?
ខ៖ មិនដែរបានឃើញមុខយ៉ាងម៉េចផង។
ក៖ ប៉ុន្តែឪពុកអ៊ុទាន់?
ខ៖ ឪពុកទាន់ខ្ញុំមើលថែហ្នឹងដៃខ្ញុំគាត់ក្រុនរងាហាសណាស់។
ក៖ បាទៗអ៊ុប៉ុន្តែឪពុកស្លាប់ហ្នឹងអស់ប៉ុន្មានឆ្នាំហើយអ៊ុ?
ខ៖ ហាសយូរហើយចូលម្ភៃឆ្នាំហើយទេដឹងយូរណាស់ហើយ!
ក៖ ចឹងអ៊ុហោស?
ខ៖ បាទ!
ក៖
អ៊ូចុះអ៊ុគិតថាអើដូចជាឪពុកម្តាយរបស់អ៊ុម្តាយរបស់អ៊ុអ៊ុអត់ដឹងថាស្លូតរឺមួយក៏កាចទេណោះអ៊ុណោះ?
ខ៖ អត់ដឹង។
ក៖ ប៉ុន្តែឪពុករបស់អ៊ុស្លូតរឺមួយក៏កាច?

ខ៖ បាទ!
ក៖ ឪពុករបស់អ៊ីស្លូតរឺមួយក៏កាច?
ខ៖ មធ្យម។
ក៖ មធ្យមហោស?
ខ៖ បាទ!
ក៖ មិនកាចមិនស្លូត?
ខ៖ មិនកាចក៏មិនស្លូត។
ក៖
អ៊ូបាទចុះអ៊ីគិតថាជីដូនជីតាខាងឪពុកអ៊ីស្គាល់ឈ្មោះគាត់ទេយាយតាខាងឪពុកហាស?
ខ៖ យាយតាខាងឪពុកអត់ស្គាល់។
ក៖ ឈ្មោះក៏អត់ស្គាល់ដែរហោស?
ខ៖ អត់។
ក៖ អ៊ូចុះយាយតាខាងម្តាយអត់ស្គាល់ដែរ?
ខ៖ អត់ស្គាល់ទេ។
ក៖ អ៊ូបាទ!
ខ៖ បើលោកពុកបានស្គាល់លោកពុកខាងម្តាយហាស!
ក៖ បាទ!
ខ៖ បានស្គាល់។
ក៖ អ៊ីអត់ស្គាល់ទេណោះ?
ខ៖ ខាងលោកពុកអត់ស្គាល់។
ក៖ អ៊ូបាទអ៊ីចុះអ៊ីគិតថាអ៊ីមករស់នៅហ្នឹងយូរនៅអ៊ី?
ខ៖ ខ្ញុំមកនៅនេះ?
ក៖ បាទ!
ខ៖ ម្ភៃជាងទេដឹង។
ក៖ ម្ភៃឆ្នាំជាងហោស?
ខ៖ បាទ!
ក៖ អ៊ូចុះពីមុនអ៊ីនៅណា?
ខ៖ ខ្ញុំនៅចំបក់តាំងក្រសាំងនេះ។
ក៖
អ៊ូបាទអ៊ីចុះអ៊ីគិតថាដូចជាអ៊ីមានបងប្អូនកូនចៅណាដែរទៅរស់នៅក្រៅប្រទេសអត់អ៊ី?
ខ៖ អត់មាន។
ក៖ ទៅនៅថៃនៅអីអត់មានដែរ?
ខ៖ អត់មានទៅ។
ក អ៊ីប្រពន្ធរបស់អ៊ីឈ្មោះអីគេ?
ខ៖ ប្រពន្ធបង្កើតមុនហោស?
ក៖ អ៊ូអ៊ីមានប្រពន្ធពីរហោស?
ខ៖ ប្រពន្ធខ្ញុំមុនស្លាប់។
ក៖ អ៊ូ!
ខ៖ នេះប្រពន្ធនៅក្រោយ។
ក៖ ប៉ុន្តែប្រពន្ធអ៊ីមុនហ្នឹងមានកូនប៉ុន្មាន?
ខ៖ បាទហ្នឹងកូនខ្ញុំប្រាំនាក់ហ្នឹងឯង!
ក៖ អ៊ូចុះប្រពន្ធក្រោយ?
ខ៖ មួយណុង។
ក៖ មួយហោស?
ខ៖ បាទ!

ក៖ អ្ងុប៉ុន្តែកូនមុនហ្នឹងអើពួកគាត់មានគ្រួសារអស់នៅអ៊ុ?
ខ៖ បាទ!
ក៖ ប្រពន្ធអ៊ុកូនមុនហ្នឹងមានគ្រួសារអស់នៅ?
ខ៖ បែជាមានអស់ទេដឹងគេបែកខ្ញុំតាំងពីយូរទៅហើយ!
ក៖ អ្ងុប៉ុន្តែគាត់អត់ដែរទាក់ទងជាមួយអ៊ុទេណេះ?
ខ៖ គេអត់ចូល។
ក៖ អ្ងុចុះពួកគាត់អត់ដែរមកលេងទេណោះអ៊ុ?
ខ៖ អត់មិនដែរមកទេតាំងពីខ្ញុំបានប្រពន្ធមកនេះ។
ក៖ អ្ងុចុះអើដល់ពេលប្រពន្ធក្រោយនេះមានកូនមួយ?
ខ៖ បាទ!
ក៖ កូនហ្នឹងប៉ុណ្ណាអ៊ុ?
ខ៖ នេះកូនប្រអែកសសរ។
ក៖ អ្ងុបានអ៊ុចុះអ៊ុគិតថាដូចជាអ៊ុការជាមួយប្រពន្ធក្រោយអស់រយះពេលប៉ុន្មាន?
ខ៖ ដឹងប៉ុន្មានដឹងប៉ុន្មានឆ្នាំហើយទេភ្លេចទៅហើយ
ភ្លេចទៅហើយដឹងប៉ុន្មានឆ្នាំទេ។
ក៖
អ្ងុចុះអ៊ុគិតថាដូចជាចឹងអ៊ុស្គាល់អ៊ុស្រីប្រពន្ធរបស់អ៊ុក្រោយហ្នឹងតាមរយះម៉េចទៅ
អ៊ុម៉េចបានអ៊ុស្គាល់?
ខ៖ ខ្ញុំមកលេងផ្ទះបងនេះបងថ្លៃខ្ញុំ។
ក៖ អ៊ុមកលេងហ្នឹងហោស?
ខ៖
មកលេងនេះឯងប៉ុន្តែគាត់ទៅអ៊ុព្រៃហោសខ្ញុំរាប់អានគាត់ទៅក៏មកលេងផ្ទះគាត់
។
ក៖ អ្ងុ!
ខ៖ ទៅក៏យើញប្រពន្ធសព្ទថ្ងៃនេះក៏អើអោយបងមកចូលដណ្តឹងអោយទៅ។
ក៖ អ្ងុអោយគាត់ចូលដណ្តឹងអោយ?
ខ៖ បាទ!
ក៖ អ្ងុប៉ុន្តែដូចជាប្រពន្ធអ៊ុអាយុប៉ុន្មានហើយ?
ខ៖ ប៉ុន្មានទេសាមបីអ្ងុសែបីហើយ!
ក៖ សែបីហោស?
ខ៖ សែបីសែបួនហើយ!
ក៖ អ្ងុបានចុះអ៊ុដែរយើញគ្នាពីមុនអត់?
ខ៖ មិនដែរទេមិនដែរជួបទេ។
ក៖ អត់ដែរជួបពីមុនទេណោះអ៊ុ?
ខ៖ អត់ដែរជួបទេទើបខ្ញុំមកលេងជួបទៅវិញអោយបងទៅដណ្តឹងអោយ។
ក៖ អ្ងុបានអ៊ុបានចុះអ៊ុគិតថាអើអ៊ុធ្លាប់បានរៀនខ្មែរពីមុនទេអ៊ុ?
ខ៖ ខ្ញុំមិនចេះអក្សរទេ។
ក៖ អត់ចេះទេហោស?
ខ៖ បាទ!
ក៖ អ៊ុអត់ដែរបានចូលរៀនទេហោស?
ខ៖ មិនដែរបានចូលរៀនទេ។
ក៖ អ្ងុចឹង..?
ខ៖ នាំបងប្អូនធ្វើជាប់រវល់រហូតហោស!
ក៖ រវល់បានអ៊ុចុះអ៊ុគិតថា..?
ខ៖
ខ្ញុំជំនាន់ប៉ុលពតបានអីមិនចេះអក្សរទេប៉ុន្តែដែរគ្មាននរណាចេះជាងសិស្សខ្ញុំជិះ

សេះគ្រប់គ្នាម៉ោងមួយម៉ោងពីរចេះតែទៅៗហើយបានគេហុចសេះទៅគេគេថា
ឈ្មោះបងឯងចឹង។
ក៖ បានអ៊ីបាន!
ខ៖
ទៅបងឯងមើលទៅឈ្មោះបងឯងចេះបណ្តោយខ្ញុំស្មានតែខ្ញុំទៅហើយនៅក្រោល
គោហើយសេះមួយហោស!
ក៖ ដោយសារមានតែអ៊ីមួយចេះ?
ខ៖ បានមានពីណាចេះដិះសេះ។
ក៖ អ៉ូបានអ៊ីបាន!
ខ៖ ជំនាន់នោះ។
ក៖ បានអ៊ីចុះអ៊ីគិតថាចឹងដូចជាអ៊ីអត់ដែរបានរៀនពីមុនទេ?
ខ៖ អត់បានរៀនទេ។
ក៖ ចុះភាសាថៃអ៊ីចេះអត់អ៊ី?
ខ៖ អើរិតតែទៅទៀតហើយ!
ក៖ រឹតតែអត់ចេះទៀតហើយណេះអ៊ីណេះ?
ខ៖ រឹតតែទៅទៀតហើយ!
ក៖ អ៉ូបានអ៊ីចុះអ៊ីគិតថាអ៊ីធ្លាប់ធ្វើស្រែចំការណេះអ៊ីណេះ?
ខ៖ បានធ្វើតែស្រែបន្តិចបន្តួចហ្នឹងហើយ!
ក៖ អ៉ូចំការអ៊ីធ្លាប់ធ្វើអត់?
ខ៖ ចំការមិនដែរបានធ្វើទេអត់មានដីស្រែចំការ
មានតែដីស្រែបន្តិចបន្តួចគ្មានចំការផង។
ក៖ អ៉ូបានអ៊ីបានចុះអ៊ីគិតថានៅស្រែភាគច្រើនអ៊ីធ្វើអីគេខ្លះទៅអ៊ីនៅស្រែ?
ខ៖
ធ្វើអីធ្វើតែស្រែតែម៉ងឯងហ្នឹងហើយលើកភ្លឺលើកអីតិចតួចទប់វាដើម្បីយើងទប់ទឹ
កទប់អីអោយវានៅក្នុងស្រែហ្នឹងឯង!
ក៖ អ៉ូភាគច្រើនអ៊ីធ្វើស្រែប្រាំងស្រែវស្សាអ៊ី?
ខ៖ ធ្វើស្រែវស្សាខ្ញុំអត់មានម៉ាស៊ីនមានអីហ្នឹងគេធ្វើតែស្រែវស្សា។
ក៖ អ៉ូស្រែវស្សាគ្រាន់ថារកអត់សូវបានណេះអ៊ីណេះ?
ខ៖ បានវា..!
ក៖ ស្រែប្រាំងរកបានច្រើនជាងណេះ?
ខ៖ ស្រែប្រាំងគេដាក់ជីដាក់អីទៅគេបូមទឹកបូមអីទៅវានៅមួយទៀត។
ក៖ អ៉ូ!
ខ៖ ខ្ញុំវាខ្វះឧបករណ៍សំរាប់ប្រើប្រាស់។
ក៖ អ៉ូបាន!
ខ៖ ចឹងហើយវាធ្វើតែស្រូវវស្សាទៅ។
ក៖
អ៉ូចុះអ៊ីគិតថាដូចជាចឹងអ៊ីគិតថាតាំងពីក្មេងរហូតមកដល់ឥឡូវការងារអីគេខ្លះ
ដែរអ៊ីធ្លាប់ធ្វើអ៊ី?
ខ៖ ខ្ញុំពីក្មេងមុនដំបូងមកខ្ញុំឥដ្ឋមកដាក់ឡ។
ក៖ អ៉ូចុះអ៊ីគិតថាដល់ពេលធំឡើងអ៊ីនៅតែធ្វើស្រែធ្វើរកត្រីដដែរ?
ខ៖ បានធ្វើស្រែរកត្រីហូបខ្លួនឯងគ្មានបានលក់បានដូរទេ។
ក៖ ចុះអ៊ីគិតថាដូចជាអើអ៊ីធ្លាប់លក់ដូរពីមុនទេ?
ខ៖ លក់ដូរអី?
ក៖ លក់ត្រីលក់អីធ្លាប់លក់ទេ?
ខ៖ អ៉ូរកមិនសូវបានលក់ប៉ុន្មានទេរកជួនកាលទៅបានជួនកាលទៅអត់។
ក៖ អ៉ូបានអ៊ីបានចុះអ៊ីគិតថាដូចជាមាន់ ទា ជ្រូក គោ ក្របីអ៊ីដែរចិញ្ចឹមអត់អ៊ី?
ខ៖ ទេមាន់ចិញ្ចឹមតើមាន់ចិញ្ចឹមមេប៉ុន្មានពីរបី។

ក៖ អ្ហ៉ឥឡូវអ៊ីនៅតែចិញ្ចឹមចឹង?
ខ៖ នៅតែចិញ្ចឹមប៉ុនមេងាប់អស់ទៅហើយនៅសល់មេពីរ។
ក៖ អ្ហ៉ប៉ុន្តែកាលពីមុនអ៊ីធ្លាប់ចិញ្ចឹម?
ខ៖ ធ្លាប់ដែរតើ!
ក៖ ជ្រូក ទា គោ ក្របី?
ខ៖ អ្ហ៉គោក្របីមិនដែរមានទេខ្ញុំ។
ក៖ អត់ដែរមានទេណោះអ៊ី?
ខ៖ អត់ដែរមានទេទទេ។
ក៖ អ្ហ៉!
ខ៖ ទៅណាមកណាជួលតែគេ។
ក៖ ចឹងអ៊ីហោស?
ខ៖
បាទប្រឹងដាក់មងដាក់សន្ទូចទៅបានលុយបន្តិចបន្តួចទៅផ្សែផ្សំទៅជួលគេទេឯ
ងដូចជាកាប់អូសដូចជាភ្ជួរអី ជួលគេភ្ជួរទៅ។
ក៖
អ្ហ៉បាទអ៊ីចុះអ៊ីគិតថាអើជីវិតរបស់អ៊ីអ៊ីគិតថាមានការផ្លាស់ប្តូរអីគេខ្លះទៅអ៊ីតាំង
ពីក្មេង?
ខ៖ ទៅផ្លាស់នៅកន្លែងណា។
ក៖ ចុះជីវភាព សុខភាពម៉េចដែរអ៊ីឥឡូវ?
ខ៖ សុខភាពដូចជាប្រែប្រួលដែរហើយ!
ក៖ ប្រែលប្រួលណោះអ៊ី?
ខ៖ បាទដូចជាធ្វើទុកក្បាលពោះវៀន ក្រពះអី។
ក៖ អ្ហ៉បាទអ៊ី!
ខ៖ ប៉ុនឥឡូវនេះខ្ញុំវារៀងអន់តិចប៉ុនវាឥឡូវមិនដែរលេបថ្នាំ
បើមុនបើខ្ញុំធ្វើការធ្ងន់នេះមួយចំហៀងក្បាលនេះដូចគេពុះចឹង។
ក៖ អើម៉េចចឹងអ៊ី?
ខ៖
ដឹងម៉េចឥឡូវនេះរៀងអន់តិចហើយអត់សូវធ្វើការធ្ងន់ហាសអោយតែធ្វើការធ្ងន់
ត្រឹមនេះមកខាងនេះខាងឆ្វេងអត់អី។
ក៖ អ្ហ៉បាទអ៊ីបាទចុះអ៊ីគិតថាជីវភាពសុខភាព
បើសុខភាពរៀងធូរជាងមុនហើយណោះអ៊ី?
ខ៖ ធូរជាងមុនតិច។
ក៖ ចុះជីវភាពជីវភាពរៀងខ្សត់ខ្សោយ?
ខ៖ បាទវាអន់ខ្សោយជាងមុន។
ក៖ អ្ហ៉បាទអ៊ី!
ខ៖ មួយរយភាគរយហើយអន់។
ក៖ បាទអ៊ីចុះអ៊ីគិតថាដូចជាម្ហូបអីដែរអ៊ីចូលចិត្តហូប?
ខ៖ និយាយរួមទៅខ្ញុំដូចជាគ្មានចូលចិត្តអីត្រូវចូលចិត្តផងដេកខ្ចិល
និយាយរួមទៅគ្មានអាជីវកម្មដូចថាទិញអីរបស់អី
ត្រូវអាឯងឃ្លានអីមិនសូវទិញហូបលុយវាគ្មានហោស!
ក៖ អ្ហ៉បាទអ៊ី!
ខ៖
ចឹងហើយដូចថាយើងចង់ស៊ីអ្ហ៉ហូបសាច់ជ្រូកសាច់គោអីយើងគ្មានលុយមិនបាន
ហូបអី។
ក៖ បាទត្រូវអ៊ី!
ខ៖ ហ្នឹងយើងមានតែត្រី។

ក៖ ចុះអ៊ីគិតថាដូចជាល្បែងប្រជាប្រិយ៍អីលាក់កន្សែង ទាញព្រាត ចោលឈូង
ជោះអង្ពុញអ៊ីពីមុនអ៊ីធ្លាប់លេងទេអ៊ី?
ខ៖ ធ្លាប់តើ!
ក៖ ធ្លាប់លេងនៅណាក្នុងភូមិហ្នឹងអ៊ីនេះ?
ខ៖ ក្នុងភូមិកាលនៅពីកំលោះលេង។
ក៖ អូ់លេងដែរអ៊ីហោស?
ខ៖ បាទ!
ក៖ អូ៉!
ខ៖ លេងលាក់កន្សែងទាញព្រាត។
ក៖ ភាគច្រើនទៅលេងនៅណាអ៊ី?
ខ៖ ខ្ញុំនៅអ៊ីច្របក់ណុងឯងតាំងក្រសាំងហ្នឹង!
ក៖ អូ់កាលរស់នៅជាមួយអ្នកភូមិអីហាសណេះអ៊ី?
ខ៖ បាទលេងតាមវត្តយើង។
ក៖ អូ៉បាទអ៊ីចុះអ៊ីគិតថាដូចជាអ៊ីចេះច្រៀងទេ?
ខ៖ អត់ចេះ។
ក៖ តែចូលចិត្តច្រៀងអត់អ៊ី?
ខ៖ អត់ទេអត់ចេះផង។
ក៖ តែអ៊ីចូលចិត្តស្តាប់ចំរៀងទេអ៊ី?
ខ៖ ខ្ញុំចូលចិត្តតើ!
ក៖ ចូលចិត្តណេះអ៊ី?
ខ៖ ចូលចិត្តបើកវិទ្យស្តាប់តែចំរៀង។
ក៖ អូ៉!
ខ៖ ចំរៀងស្តាប់លោកទេសអីទៅយើងមិនចេះអក្សរក៏ចេះស្តាប់លោកទេសលោកអី
លោកទេសទេសពន្យល់យើងពីនេះមួយពីនោះមួយទៅ។
ក៖ បាទអ៊ីបាទ!
ខ៖ យើងមិនបានទៅវត្តទៅវ៉ាយើងបានស្តាប់លោកទេសដែរ។
ក៖ បាទអ៊ីចុះអ៊ីគិតថាដូចជាល្ខោនយីកេ អាយ៉ៃអីអ៊ីចូលចិត្តមើលទេ?
ខ៖ ចូលតើចូលចិត្តមើល។
ក៖ ចូលចិត្តមើលដែរណោះអ៊ី?
ខ៖ អើអោយតែថាលឺជិតៗ។
ក៖ ទៅមើលទាល់ភ្លឺ?
ខ៖ ទៅហើយគេចប់ត្រឹមណាមកត្រឹមស្មាហ្នឹង!
ក៖ បាទមើលទាល់ចប់ណេះអ៊ីណេះ?
ខ៖
បាទដោយសារគេមិនចាំបាច់ទៅទេតែគេដាក់អកកណ្តុងអីនៅវត្តនេះមើលហែង
ទាល់ចប់នៅវត្តយើងនេះហាសណាស់។
ក៖
អូ៉បាទអ៊ីចុះអ៊ីគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសារអ៊ីចេះលេងឧបករណ៍
ភ្លេងទេអ៊ី?
ខ៖ អត់មានមានអាតូចមួយមិញហ្នឹងឯង!
ក៖ អូ៉ចុះប្អូណជីដូនមួយប្អូនថ្លៃប្អូនអីបង?
ខ៖ អត់មានពីណាចេះទេ។
ក៖ អត់មាននរណាគេចេះទេណេះ?
ខ៖ អត់។
ក៖
អូ៉ចុះអ៊ីគិតថាអើផ្ទះរបស់អ៊ីមានលក្ខណះបែបណាអ៊ីកាលអ៊ីនៅជាមួយឱពុកម្តាយ
ពីមុនផ្ទះម៉ែចទៅ?

ខ៖ អើផ្ទះតូចទេ។
ក៖ ចឹងហោសអ៊ុ?
ខ៖ បាទ!
ក៖ ចុះដល់ពេលអ៊ុមានគ្រួសារឥឡូវផ្ទះម៉េចទៅ?
ខ៖ នេះកូនខ្ទមនេះតែមើលទៅឃើញនេះ។
ក៖ នេះហោសអ៊ុ?
ខ៖ បាទ!
ក៖ អ្ហ៎ចុះអ៊ុ..?
ខ៖ ណែហេតុតែថាវេទនាធ្វើកម្មករគេស៊ីឈ្នួលស្នងគេស្រូវរសូវពីរនាក់យាយតា។
ក៖ អ្ហ៎ចុះប្រពន្ធអ៊ុធ្វើអីដែរ?
ខ៖ ទៅស្នងស៊ីឈ្នួលស្នងអោយគេ។
ក៖ អ្ហ៎បាទអ៊ុទៅស្នងអោយគេដែរទៅ?
ខ៖ បាទមួយរសូវមួយផុតចុងផុតដើម។
ក៖ ចុះមួយថ្ងៃគេអោយប៉ុន្មានទាំងប្តីទាំងប្រពន្ធ?
ខ៖ មួយម៉ឺនជ្រាំ។
ក៖ ទាំងប្តីទាំងប្រពន្ធបីម៉ឺនហើយណេះ?
ខ៖ បាទ!
ក៖ ប៉ុន្តែមួបអាហារខ្លួនឯងទៀត?
ខ៖ ខ្លួនឯងបាយខ្លួនយើង។
ក៖ ប៉ុន្តែទៅស្នងឆ្ងាយៗអត់?
ខ៖ ឆ្ងាយប៉ុន្តែបានម្អូន។
ក៖ ជូនទៅ?
ខ៖ ជូនម៉ូតូទៅ។
ក៖ អ្ហ៎ចុះអ៊ុគិតថាដូចជាអ៊ុមានជំនាញអីដែរអ៊ុចេះស្នាត់ជំនាញអត់អ៊ុ?
ខ៖ រកអីស្នាត់មិនឃើញទៀតណា។
ក៖ អ្ហ៎!
ខ៖ ខ្ញុំមិនសូវប្រសប់អីទេមិនសូវចេះអីទេ។
ក៖
អ្ហ៎បាទអ៊ុបាទចុះអើម្តាយឪពុករបស់ធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុទេលក្ខណៈវេញ
រ្លី ក្ងរ្ស អ៊ុចេះឡើងគ្នោកទេអ៊ុ?
ខ៖ អត់ទេ។
ក៖ ប៉ុន្តែដូចជាវេញរ្លី ក្ងរ្សរធ្វើផ្តៅអ៊ុអត់ចេះដែរ?
ខ៖ ចេះតែវេញខ្សែល្អែក។
ក៖ វេញខ្សែល្អែក?
ខ៖ តូចៗ។
ក៖ អាហ្នឹងវេញធ្វើអីគេអ៊ុ?
ខ៖ វេញខ្សែគោយើង។
ក៖ អ្ហ៎!
ខ៖ ខ្សែគោខ្សែក្របីយើង។
ក៖ បាទអ៊ុបាទចុះអ៊ុវេញៗធ្វើអីអ៊ុ?
ខ៖ វេញធ្វើខ្សែប្រគត់ ខ្សែស៊ីម៉ង។
ក៖ អាធ្វើខ្សែចំណងគោហ្នឹងហោសអ៊ុ?
ខ៖ បាទ!
ក៖ អាហ្នឹងលក់បានមួយប៉ុន្មានអ៊ុ?
ខ៖ ទេមិនដែរលក់ទេប្រើតែខ្លួនឯងៗ!
ក៖ អ្ហ៎!
ខ៖ តែឥឡូវទេចងគោគេប្រើតែខ្សែលីងឡងគេលែងភ្លេចអស់ហើយអាហ្នឹង!

ក៖ បាទអ៊ីបាទ!
ខ៖
ដើរទៅថ្ងៃគេដើរទៅចូលព្រៃមកបោចតែមួយក្តាប់ប៉ុនកួនដៃមកកោះដាច់មក
អង្គុយធ្លុញក្រវីបណ្តើរល្ងាចឡើងមកដល់អង្គុយវិញបាចទឹករួច។
ក៖
បាទអ៊ីបាទចុះអ៊ីគិតថាអ៊ីអាចប្រាប់ពីការលំបាករបស់អ៊ីបានទេតាំងពីក្មេងរហូត
មកដល់ឥឡូវហាសអ៊ីលំបាកអី?
ខ៖ ខ្ញុំថាការលំបាកក៏អត់សូវមានលំបាកអាស្រួលក៏មិនសូវមានស្រួល។
ក៖ ម៉េចចឹងអ៊ី?
ខ៖ ដូចថាមធ្យម។
ក៖ ពាក់កណ្តាល?
ខ៖ បាទមធ្យម។
ក៖ អ៉ូ!
ខ៖ លំបាកក៏មិនសូវលំបាកស្រួលក៏ថាមិនស្រួលវាមធ្យម។
ក៖
អ៉ូចុះអ៊ីអាចប្រាប់ពីការលំបាកអើចង់និយាយថាពីជំនាន់ដែរអ៊ីកើតទាន់បានទេ
ដូចជាអ៊ីកើតទាន់ជំនាន់លុនណុលទេអ៊ី?
ខ៖ កើតទាន់ជំនាន់អ៊ីសាវ៉ាក់។
ក៖ អ៊ីសាវ៉ាក់ទៀតហោស?
ខ៖ បាទ!
ក៖ ប៉ុន្តែអ៊ីសាវ៉ាក់អ៊ីនៅតូចហោសអ៊ីហោស?
ខ៖ បាទណែទើបកើតង៉ា។
ក៖ អ៉ូប៉ុន្តែជំនាន់ណាអ៊ីកើតទៀត?
ខ៖ បាទ!
ក៖ ធៀវគីអ៊ីកើតទាន់ទេ?
ខ៖ អត់ដឹងធៀវគីម៉េចទេ។
ក៖ អ៉ូចុះជំនាន់គេហៅដាបឈួន?
ខ៖ ក៏មិនដឹងដែរ។
ក៖ អ៉ូចុះពួកអាពួកយ៉ាគកុងធ្មេញខ្មៅពួកវៀតណាមធ្មេញខ្មៅអ៊ីទាន់អត់?
ខ៖ វៀតណាមធ្មេញខ្មៅលឺតែចាស់ៗនិយាយ។
ក៖ ប៉ុន្តែអ៊ីអើអត់ច្បាស់អ៊ីនៅតូជណោះអ៊ី?
ខ៖ អត់ច្បាស់នៅតូច។
ក៖ អ៉ូ!
ខ៖ លឺតែចាស់ៗនិយាយ។
ក៖ ចុះអ៊ីកើតទាន់គឺលុនណុល?
ខ៖ លុនណុលកើតជំនាន់លុនណុល។
ក៖ ប៉ុន្តែលុនណុលអ៊ីមានការលំបាកអីអ៊ី?
ខ៖ ទេនៅជាមួយអ៊ីជាមួយយាយអត់ដឹងថាលំបាកម៉េចផង។
ក៖ អ៉ូចុះកាលជំនាន់ណងមានគ្រាប់ផ្លោងមានអីណោះអ៊ីណោះ?
ខ៖ មាន។
ក ចុះអ៊ីគិតថា..?
ខ៖ គ្រាប់ផ្លោងផងយន្តហោះទំលាក់ផង។
ក៖ អ៉ូ!
ខ៖ និយាយពីដំបូលផ្ទះយាយខ្ញុំតែគាត់យកខ្ញុំទៅចិញ្ចឹមឆាបឡើងរបើកក្បឿង។
ក៖ អ៉ូជំនាន់ណុងហោស?
ខ៖
គាត់ធ្លាប់មើលទៅគាត់បីខ្ញុំយកទៅចូលក្នុងអាជំនាន់នោះគេហៅត្រង់សេៗហាស!

ក៖ បាទ!
ខ៖ មិនហៅចំរុះយើងណា។
ក៖
បាទដោយសារតែនៅតាមផ្ទះមួយៗគេសុទ្ធតែជីកត្រង់សេនៅក្រោមដីមែនទេអ៊ុ?
ខ៖ រួចដាក់ឈើនេះប៉ុនសសរដាក់លើ។
ក៖ ខ្លាចគីឡត្រាប់ផ្លោងមកផ្ទះ?
ខ៖ បាទបើយើងដាក់អាធំៗចឹងទៅមានតែពីឬជាន់តែបជាន់ហោស
បើចំធ្លាប់ចំម៉េចម៉ាវាត្រាន់បើ។
ក៖ អ៉ូប៉ុន្តែយើងពេលណុងអត់ត្រូវអីទេណេះអ៊ុណេះ?
ខ៖ បាទអត់មានអី។
ក៖ អ៉ូហើយ...?
ខ៖
អត់ហ៊ានធ្វើអីនៅក្រោមដើមឈើទៀតហាសខ្លាចវាយើញថាយើងធ្វើជំរកក្រោម
ដើមឈើវាដឹងថាយើងធ្វើនៅហ្នឹង!
ក៖ បាទអ៊ុ!
ខ៖ រួចទំលាក់មួយជ្រុំហ្នឹងហើយដាក់អាក្រដាស់វា។
ក៖ អ៉ូទំលាក់នៅចំហ្នឹងម៉ង?
ខ៖ បាទកណ្តាលវាលចឹងឯងយើងធ្វើជំរកហាស!
ក៖ បាទ!
ខ៖
ដាក់កណ្តាលវាលហោសដែងដូចថាវាស្លឹកគ្នោតស្លឹកអីយកទៅបិទមាត់រណ្តៅអត់
ហ៊ានធ្វើមាត់ធំទេប៉ុននេះឯងអីទេត្រាន់មួយច្រកចូល
ចូលយកស្លឹកគ្នោតមួយត្របនាំគ្នានៅសំងំក្នុងហ្នឹងឯង!
ក៖ ទាំងងងឹតចឹងទៅ?
ខ៖ តែព្រិលឡើងចូលទៅហើយដើបដាំបាយតាំងពីយប់ហោសយាយៗហាស!
ក៖ អ៉ូ!
ខ៖ ដាំបាយឆ្អិនអីឆ្អិនហោសនាំគ្នាធ្វើទឹកផឹក។
ក៖ ធ្វើអស់រយះពេលប៉ុន្មានថ្ងៃអ៊ុ?
ខ៖ ហ៉ែកាលណុងយូរដែរណាស់ហើយចូលខែទេដឹងវាតាមទំលាក់ហ្នឹង។
ក៖ នៅភូមិហ្នឹងហោស?
ខ៖ នៅអីចំបក់តាំងក្រសាំងនោះស្រុកកំណើតខ្ញុំហាសណាស់។
ក៖ បាទៗចុះអ៊ុគិតថាពេលប៉ុលពតពេលណុងអោយយើងទៅណាអ៊ុ?
ខ៖ ពេលប៉ុលពតដែរខ្ញុំធ្វើ?
ក៖ បាទ!
ខ៖ មករត់នេសាទយើងទៅសមុទ្រ។
ក៖ ចុះអើប៉ុលពតគេអោយអ៊ុធ្វើអីគេជំលាសអ៊ុទៅណាហើយអ៊ុធ្វើការងារអីគេទៅ?
ខ៖ ទេមានជំលាសអី។
ក៖ នៅណុងដដែលហោសនៅចំបក់តាំងក្រសាំង?
ខ៖ នៅត្រាន់ថាយើងមកនៅតាមអង្គភាព។
ក៖ អ៉ូប៉ុន្តែនៅស្រុកហ្នឹងទេ?
ខ៖ បាទ!
ក៖ អ៉ូហើយចុះហើយអើអ៊ុគិតថាដូចជារបបអាហារម៉េចដែរអ៊ុ?
ខ៖ អើរបបអាហារពិបាកនិយាយដែរ។
ក៖ អ៉ូ!
ខ៖ ដូចគេថាពួកអ្នកគ្នាណែដូចអត់ដូចខ្ញុំហាស!
ក៖ បាទអ៊ុបាទ!
ខ៖ អត់ដូចខ្ញុំដូចថាបបរមួយវែកមកស្រង់យកកាកបបរបានមួយស្លាបព្រា។

ក៖ អ្វ៉ពេលណុងហូបបបរណេះអ៊ីណេះ?
ខ៖ ហូបបបរជំនាន់ប៉ុលពតហោស!
ក៖ បាទអ៊ីបាទចុះអ៊ីគិតថាដូចជាចឹងយើងបែកគ្នាពីឪបងប្អូនអស់ហើយណេះ?
ខ៖ ខ្ញុំបែកអស់ហើយ!
ក៖ រួចចុះបងប្អូនឪពុកម្តាយទៅណា?
ខ៖ ស្លាប់អស់ហើយ!
ក៖
អ្វ៉ហើយចុះឪពុកអ៊ីពេលដែរយើងបែកពេលដែរយើងមកជុំគ្នារិញយើងមកជុំនៅ
ណាទៅ?
ខ៖ ជុំនៅក្នុងស្រុកនៅភូមិហ្នឹង!
ក៖
អ្វ៉ហើយចុះពេលណុងបាត់ខ្លួនអស់ប៉ុន្មាននាក់ហើយស្លាប់អស់ប៉ុន្មាននាក់ទៅអ៊ី?
ខ៖ កាលដែរដាច់ណុងស្លាប់តែមួយទេនៅទាំងអស់ហ្នឹងតើ!
ក៖ អ្វ៉ចុះអ៊ីគិតថាពេលដែរដាច់ប៉ុលពតហើយពេលណុងយើងធ្វើការងារអីគេអ៊ី?
ខ៖ អើកាលនោះឯងធ្វើអីដើរតែកោសគួរដើរ។
ក៖ រើសអីគេអ៊ី?
ខ៖ ដើរតែកោសគួរស្រូវយើង។
ក៖ កោសគួរស្រូវហោស?
ខ៖ បាទ!
ក៖
អ្វ៉ចុះអ៊ីគិតថាដូចជាពេលណុងយើងលំបាកអីទៅអ៊ីដោយសារតែពេលណុងយើង
ត្រូវដូរស្រូវយកអង្កររឺមួយក៏ ដូចអង្ករយកម្ហូបវិញណេះអ៊ីណេះ?
ខ៖ បាទ!
ក៖ អត់មានចាយលុយទេណេះអ៊ីណេះ?
ខ៖ អត់មានទេ។
ក៖ ចុះពេលណុងយើងលំបាកខ្លាំងអត់អ៊ី?
ខ៖ លំបាករឿងលំបាកហើយ!
ក៖ ប៉ុន្តែអើពេលណុងយើងនៅជាមួយគ្រួសារយើងណេះអ៊ីណេះ?
ខ៖
បាទប៉ុននៅខ្ញុំវាគ្រាន់ថាយាយគាត់ថែរក្សាយើងថាអើយចៅឯងយ៉ាប់ខ្លាំងណាស់។
ក៖ បាទ!
ខ៖ យាយជំនាន់កាលមិនទាន់ដាច់យាយរត់ហើយចៅឯង!
ក៖ បាទអ៊ី!
ខ៖
បានថារស់ហ្នឹងខ្ញុំព្រោះខ្ញុំពេលនេះខ្ញុំសុំមេមកសុំមេមកឥឡូវមេគាត់ជួយលាក់ដែរ
អាខោវែងយើងដាក់ពីរជើងខោមកអង្ករ។
ក៖ អ្វ៉!
ខ៖ ត្រីងៀកមកគាត់អោយមកគាត់ច្រកបំបែកអោយត្រីងៀតត្រីច្តោរយើង។
ក៖ បាទអ៊ី!
ខ៖ រួចទៅមកពាក់លើខ្នងសេះខាងមុខខ្ញុំបានព្រុចយកមកអោយគាត់
គាត់ថាអើចៅអញ់សុខចិត្តក្រអញ់កុំអោយងាប់បើចៅឯងមកកុំបានចៅឯងប
ណ្ពុះៗអោយអញ់ប៉ុនយាយចៅអើយមិនដែរហ៊ានថ្ងៃទេ
គេជួបម៉ោងដប់ម៉ោងដប់មួយបានហ៊ានបង្កាត់ភ្លើងដាក់ដាំបាយហូប។
ក៖ បាទអ៊ីបាទ!
ខ៖ ពេលថ្ងៃទៅឈើច្រតមួយគាត់ដើរចារកោងៗ។
ក៖ បាទអ៊ី!
ខ៖ ទៅកន្លែងសាលាគេបានបបរយកមកហូបផ្ទះ។

ក៖ អ្ហ៉ូបាទចុះអើអ៊ីគិតថាដូចជាអើពេលណាដែរអ៊ីគិតថាសប្បាយអ៊ី?
ខ៖ សប្បាយយើងឥឡូវនេះឯងទៅសប្បាយមានតែឥឡូវទេ។
ក៖ អ្ហ៉ូឥឡូវហោសអ៊ី?
ខ៖ បាទ!
ក៖
អ្ហ៉ូចុះអ៊ីគិតថាដូចជាអើពេលដែរអ៊ីនៅក្មេងអ៊ីមានធ្លាប់គិតថាធំឡើងអ៊ីមានចង់ធ្វើអីមួយទេអ៊ី?
ខ៖ អត់អត់មានគិតយើញផង។
ក៖ គិតអត់យើញទេហោស?
ខ៖ គិតអត់យើញ អត់មានគិតអីគិតយើញពេលផឹកពេលស៊ីហោស!
ក៖ អ្ហ៉ូគិតយើញតែពេលផឹកស៊ីពេលស៊ីហោសអ៊ី
អាពេលផឹកពេលស៊ីអ៊ីនឹកយើញសប្បាយទេអ៊ី?
ខ៖ សប្បាយហូបច្រើង។
ក៖
បាទអ៊ីចុះបើសិនជាខ្ញុំមានសំនួរចុងក្រោយមួយបើសិនចង់អោយអ៊ីផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយអ៊ីគិតថាមានអីដែរចង់ផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយទេអ៊ី?
ខ៖ អត់មានពាក្យផ្ទើរផ្តាំផង។
ក៖
អ្ហ៉ូបាទអ៊ីចុះបើសិនជាលក្ខណះចង់អោយកូនចៅអីជៀសវៀងអីមួយពីអំពើដែរអត់ល្អក្នុងសង្គមអីចឹងហាស អ៊ីគិតថាមានអីចង់ផ្តែផ្តាំរឺមួយក៏ពិភាក្សាអី?
ខ៖ អត់មានពាក្យនិយាយម៉េច។
ក៖ អត់មានពាក្យអីទេ?
ខ៖ អត់។
ក៖
អ្ហ៉ូអ៊ីឯងផ្តែផ្តាំថាកូនអោយដើរតាមកន្លងអ៊ីឯងអីចឹងកូនគាត់ហោសចឹងអត់អីទេណេះអ៊ី?
ខ៖ ផ្តាំវាម៉េចក៏ផ្តាំមិនកើតផ្តាំប្រាប់វាម៉េចក៏ប្រាប់មិនកើត។
ក៖ បាទចឹងចុងក្រោយអរគុណអ៊ី!
ខ៖ បាទ!
ក៖ ដែរបានអោយខ្ញុំពិភាក្សាជាមួយអ៊ីទាក់ទងពីប្រវត្តិអ៊ីចឹងហាសអ៊ី!
ខ៖ បាទ!
ក៖ អរគុណច្រើនអ៊ី។